# ការវាយតម្លៃបឋម

ប្រកាសអន្តរក្រសួងស្តីពីការហាមឃាត់ការប្រើប្រាស់ពលកម្មក្នុងពន្ធនាគារ ដើម្បីផលិតទំនិញនាំចេញ

ក្រសួងពាណិជ្ជកម្ម រួមជាមួយក្រសួងមហាផ្ទៃ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខយោង: [០០០០០១]

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១២

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១២

ទំនាក់ទំនង:

| | ឈ្មោះ | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|
| IA-ទទួលបន្ទុក | លោក ម៉េង សុងឃាង | ០១២ ៨២៥ ៩៩៨ | mengkheang06@yahoo.com |
| IA-ជំនួស | កញ្ញា ហាង្ស សុជាតា | ០៩៧ ៩៥៩ ៩៩៩២ | hang.socheata@ymail.com |
| ORIA-ទទួលបន្ទុក | លោកស្រី ស៊ីម រ័ត្ន[illegible] | ០១២ ៩៥៨ ៨៦៥ | srothakh@yahoo.com |
| ORIA-ជំនួស | លោក ហេង សុភ័ក្រ្តបញ្ញា | ០១៦ ៨៥៧ ៧៥៩ | pangha.h@gmail.com |

អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ប្រកាសដែលបានស្នើឡើង នឹងហាមឃាត់នូវការប្រើប្រាស់ពលកម្មពន្ធនាគារក្នុងរោងចក្រ ឬផលិតទំនិញដែលនឹងត្រូវនាំចេញពីប្រទេសកម្ពុជា។ ដូចនេះ ពន្ធនាគារអាចអនុញ្ញាតឲ្យអ្នកទោសនៅក្នុងពន្ធនាគារចូលរួមក្នុងវិស័យរោងចក្រឬផលិតកម្មផ្សេងៗទៀតដែលជាផ្នែកមួយនៃការស្តារនិតិសម្បទារបស់ពួកគេឡើងវិញប៉ុន្តែក្នុងករណីដែលទំនិញទាំងនោះត្រូវបានលក់តែក្នុងទីផ្សារក្នុងស្រុកប៉ុណ្ណោះ។

ជម្រើសនេះ នឹងមិនដាក់លក្ខខណ្ឌឬទណ្ឌកម្មលើពន្ធនាគារឬអ្នកទោសឡើយ។ ជំនួសមកវិញធុរកិច្ចដែលជាប់ពាក់ព័ន្ធក្នុងការផលិតឬនាំចេញទំនិញសម្រាប់លក់នៅបរទេស ត្រូវបង្ហាញថាទំនិញទាំងនេះគឺត្រូវបានផលិតដោយគ្មានការប្រើប្រាស់ពលកម្មពន្ធនាគារ។

ចំពោះធុរកិច្ចណាដែលទទួលទំនិញដែលផលិតដោយប្រើប្រាស់ពលកម្មពន្ធនាគារ រួចហើយធ្វើការនាំចេញទំនិញទាំងនោះ នឹងទទួលរងការដាក់ទណ្ឌកម្ម។ ប្រការនេះ ដូចគ្នានឹងជម្រើសទីមួយ។ ការបំពានច្បាប់លើកដំបូង នឹងទទួលរងការផាកពិន័យជាទឹកប្រាក់ចំនួន ៥០០០០$ និងការហាមឃាត់ការនាំចេញរយៈពេលបីខែ។ ទណ្ឌកម្មទាំងនេះគឺត្រូវអនុវត្តចំពោះអ្នកនាំចេញនិងអ្នកជាប់កិច្ចសន្យាផលិត

| |
|---|
| បន្តទាំងឡាយណាដែលជាប់ពាក់ព័ន្ធក្នុងដំណើរការផលិតកម្មរវាងទំនិញដែលចេញពីពន្ធនាគារនិងត្រូវបានគេនាំចេញ។ ក្នុងករណីមានការបំពានច្បាប់ម្តងទៀត ធុរកិច្ចនឹងទទួលរងការដកហូតសិទ្ធិក្នុងការនាំចេញនៃធុរកិច្ចដែលជាប់ពាក់ព័ន្ធ ដោយក្រសួងពាណិជ្ជកម្ម។ |

តើសំណើនេះមានចរិកជាបញ្ញត្តិកម្មដែរឬទេ?

តើវាផ្លាស់ប្តូរឥរិយាបទធុរកិច្ចដែរឬទេ ?មែន

| ច្បាប់ | | ព្រះរាជក្រឹត្យ | | អនុក្រឹត្យ | | ប្រកាសអន្តរក្រសួង | X | សេចក្តីសម្រេច | | សារាចរ | | ផ្សេងៗ (ពិពណ៌នា) |
|---|---|---|---|---|---|---|---|---|---|---|---|---|

*សូមគូសសញ្ញាខ្វែងក្នុងប្រអប់ដែលត្រឹមត្រូវហើយ សូមពិពណ៌នាប្រសិនបើមានជម្រើសផ្សេង។*

ប្រសិនបើ "មិនមែន" ការវាយតម្លៃបឋមត្រូវបញ្ចប់រួចបន្តទៅទំព័រចុងក្រោយ / ប្រសិនបើ "មែន" បន្តទៅសំនួរបន្ទាប់។

សូមគូសរង្វង់លើ "មែន" ឬ "មិនមែន"

តើសំណើបញ្ញត្តិនេះមានផលប៉ះពាល់លើវិស័យធុរកិច្ចដែរឬទេ? មែន

ប្រសិនបើ "មិនមែន" សូមបញ្ចប់ការវាយតម្លៃបឋមរួចបន្តទៅទំព័រចុងក្រោយដើម្បីបញ្ចប់

បើ "មែន" សូមបន្តទៅសំនួរបន្ទាប់ហើយបន្តការវាយតម្លៃ។

១. បញ្ហា- ហេតុអ្វីបានជាយើងធ្វើបញ្ញត្តិកម្មនេះឡើង?

*សូមផ្តល់ភស្តុតាងជាក់ស្តែងជៀសវាងផ្តល់ជាមតិយោបល់ឬការពោលអះអាងអំពីបញ្ហា។សូមគូសរង្វង់លើ "មែន" ឬ "មិនមែន"។*

| ប្រធានបទទូទៅ | សំណើបញ្ញត្តិកម្មនេះនឹងដោះស្រាយ | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាពសាធារណៈនិង សុវត្ថិភាព | មិនមែន | |
| ការការពារនិងអភិរក្សបរិស្ថាន | មិនមែន | |
| សមធម៌យេនឌ័រ ការអភិរក្សសង្គមនិងវប្បធម៌ | ប្រហែល | |
| ជំរុញការប្រគួតប្រជែង | មិនមែន | |
| ការប្រមូលផ្តុំព័ត៌មាន | មិនមែន | |

| | | |
|---|---|---|
| អនុលោមតាមកិច្ចព្រមព្រៀងរបស់ (WTO) និងកិច្ចព្រមព្រៀងអន្តរជាតិនានា | មិនមែន | |

ប្រសិនបើមានបញ្ហាផ្សេងទៀតអធិប្បាយផ្តល់ភស្តុតាង

ច្បាប់ស្តីពីពន្ធនាគារថ្មីដែលត្រូវបានអនុម័តឆ្នាំ ២០១១ អនុញ្ញាតឲ្យពន្ធនាគារកម្ពុជាផ្តល់ឱកាសឲ្យអ្នកទោសទទួលយកការងារដែលមានកម្រៃនៅក្នុងផលិតកម្មកាត់ដេរសំលៀកបំពាក់និងការងារដទៃទៀតដែលជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវបានផ្តល់ដើម្បីជំរុញការស្តារឡើងវិញនូវនីតិសម្បទានិងការធ្វើសមាហរណកម្មក្នុងសង្គមរបស់ពួកគេ ក្រោយពីពួកគេបានចាកចេញពីពន្ធនាគារ។

ដោយអនុលោមតាមការច្បាប់នេះ ម្ចាស់រោងចក្រខ្លះបានចាប់ផ្តើមប្រើប្រាស់ពលកម្មពន្ធនាគារដើម្បីអនុវត្តការងារបន្ទាប់បន្សំក្នុងវិស័យកាត់ដេរសំលៀកបំពាក់និងស្បែកជើង។ ម្ចាស់រោងចក្រទាំងអស់នេះ ទំនងជាត្រូវបានទាក់ទាញឲ្យប្រើប្រាស់ពលកម្មពន្ធនាគារដោយសារតែវាមានមានតម្លៃថោកជាង មានពាក់ព័ន្ធជំលោះផ្នែកការងារតិច និងមានវិន័យច្រើន ហើយពលកម្មពន្ធនាគារត្រូវបានគេប្រើ ដើម្បីដោះស្រាយបញ្ហាកង្វះខាតការផ្គត់ផ្គង់ពលកម្ម ដើម្បីឲ្យទាន់កាលកំណត់នៃការបញ្ជាកម្មង់ទិញ។

ទោះបីជាយ៉ាងណា ដៃគូរពាណិជ្ជកម្មចំបងរបស់កម្ពុជាបានលើកឡើងនូវក្តីបារម្ភចំពោះទិដ្ឋភាពនៃច្បាប់ស្តីពីពន្ធនាគារថ្មី និងបានបង្ហាញថាពួកគេនឹងរិតត្បិតការនាំចូល ប្រសិនបើពលកម្មពន្ធនាគារត្រូវបានប្រើប្រាស់នៅក្នុងផលិតកម្មទំនិញដែលពួកគេបានទិញពីកម្ពុជា។ ដោយសារតែការអនុវត្តបែបនេះ អាជ្ញាធរនៃប្រទេសកម្ពុជាមានការប្រុងប្រយ័ត្ន និងបានសម្រេចស្វែងរកមធ្យោបាយផ្សេងដើម្បីសម្រាលបញ្ហានេះ។

ម្ចាស់រោងចក្រម្នាក់ៗនៅក្នុងប្រទេសកម្ពុជា អាចជ្រើសរើសការមិនប្រើប្រាស់ពលកម្មពន្ធនាគារដើម្បីធានានូវឱកាសនៃការនាំចេញទៅប្រទេសទាំងនេះ។ ទោះបីយ៉ាងណា វាមានហានិភ័យគួរឲ្យកត់សម្គាល់ ការដែលពលកម្មពន្ធនាគារត្រូវបានប្រើប្រាស់ដោយម្ចាស់រោងចក្រណាមួយដោយចេតនាឬដោយការធ្វេសប្រហែស នឹងទទួលរងការដាក់ទណ្ឌកម្មប្រឆាំងនឹងប្រទេសកម្ពុជាដោយ សហរដ្ឋអាមេរិច និងប្រទេសប៉ែកអឺរ៉ុប ដែលការនាំចេញទៅប្រទេសទាំងនេះ មានតម្លៃស្មើនឹង២/៣នៃការនាំចេញសរុប។ នេះជាការខាតបង់ច្រើនចំពោះអ្នកផលិតនៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែង វិស័យកាត់ដេរជាវិស័យមួយដែលរួមចំណែកយ៉ាងច្រើនក្នុងចំណូលដែលបានមកពីការនាំចេញសរុបរបស់កម្ពុជា ដូចនេះជារួម ការចំណាយនេះបានបង្កឲ្យមាននូវការខាតបង់យ៉ាងច្រើនចំពោះសេដ្ឋកិច្ចកម្ពុជា។

ចំណាយទាំងនេះ ជាបន្ទុករបស់ម្ចាស់រោងចក្រទាំងអស់ ហើយមានតែអ្នកដែលប្រើប្រាស់ពលកម្មពន្ធនាគារប៉ុណ្ណោះដែលទទួលបាននូវការសន្សំសំចៃពីការប្រើប្រាស់ពលកម្មពន្ធនាគារនេះ ទាំងនេះបានបង្ហាញនូវកត្តាខាងក្រៅដែលអាចទាមទារនូវអន្តរាគមន៍របស់រាជរដ្ឋាភិបាលដើម្បីសម្រេចឲ្យបាននូវលទ្ធផលប្រកបដោយភាពជោគជ័យផ្នែកសង្គម។ 

សូមបញ្ជាក់ថាតើបញ្ញត្តិកម្មនេះនឹងធ្វើឲ្យស្ថានការណ៍ប្រសើរឡើងយ៉ាងដូចម្តេច

ប្រកាសនេះ នឹងផ្តល់នូវការធានាអះអាងដល់អ្នកទិញបរទេសថា ពលកម្មពន្ធនាគារគឺមិនត្រូវបានប្រើប្រាស់ក្នុងការផលិតកាត់ដេរសំលៀកបំពាក់និងស្បែកជើង ។ល។ ដែលទំនិញទាំងនេះត្រូវបានពួកគេនាំចូល។

២. គោលបំណង - តើយើងចង់សម្រេចអ្វី?

គោលបំណងនៃការអន្តរាគមន៍របស់រាជរដ្ឋាភិបាលនេះ ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង និងដើម្បីថែរក្សាឬបង្កើតលទ្ធភាពចូលទៅក្នុងទីផ្សារបរទេសសំខាន់ៗដូចជាសហរដ្ឋអាមេរិក និងប្រទេសប៉ែកអឺរ៉ុប សម្រាប់ម្ចាស់រោងចក្រកម្ពុជាដោយធ្វើការធានាអះអាងចំពោះអ្នកនាំចូលថា ពលកម្មពន្ធនាគារគឺមិនត្រូវបានប្រើប្រាស់ដើម្បីផលិតទំនិញដែលពួកគេនឹងទិញនោះទេ។ គោលបំណងនេះនឹងត្រូវបានវាស់វែងដោយ ៖

- ប្រទេសនិងអ្នកនាំចូលសំខាន់ៗបញ្ជាក់ថាពួកគេមិនមានការព្រួយបារម្ភពីការប្រើប្រាស់ពលកម្មពន្ធនាគារនៅក្នុងប្រទេសកម្ពុជាទៀតទេ។
- ការរក្សាកម្រិតនៃវិស័យកាត់ដេរសំលៀកបំពាក់និងការនាំចេញទំនិញផ្សេងទៀតឲ្យនៅកម្រិតដដែលឬកម្រិតខ្ពស់ជាងនេះ ដែលមានតម្លៃច្រើនជាង៣កោតដុល្លារសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ២០១០ និង ២០១១។

៣. ជម្រើស- ពិចារណាជម្រើសផ្សេងៗទាំងឡាយ

៣.ក.សូមរាយបញ្ជីនូវបញ្ញត្តិកម្ម(ដែលមានស្រាប់)ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។

១. រាជរដ្ឋាភិបាលកម្ពុជា ជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាអង្គការពលកម្មអន្តរជាតិ(ILO)។ សន្ធិសញ្ញាលេខ២៩ បានហាមឃាត់ការប្រើប្រាស់ពលកម្មដោយបង្ខំ។

២. ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជានិងច្បាប់ដែលពាក់ព័ន្ធបានផ្តល់សច្ចាប័ន ចំពោះការចូលជាសមាជិកWTO និងកិច្ចព្រមព្រៀងទ្វេភាគីស្តីពីវិស័យកាត់ដេរសំលៀកបំពាក់និងវាយនភណ្ឌរវាងសហរដ្ឋអាមេរិកក៏បានហាមឃាត់នូវការប្រើប្រាស់ពលកម្មដោយបង្ខំដែរ។

ចូរបញ្ជាក់ថាតើហេតុអ្វីបានជាលិខិតបទដ្ឋានទាំងនេះមិនទាន់គ្រប់គ្រាន់?

ច្បាប់និងសន្ធិសញ្ញាដែលមានស្រាប់ គឺជាប់ពាក់ព័ន្ធតែនឹងការប្រើប្រាស់ពលកម្មដោយបង្ខំ ដែលមានលក្ខណៈខុសពីពលកម្មពន្ធនាគារ។ ឧទាហរណ៍ អ្នកទោសដែលកំពុងបម្រើការងារដើម្បីបំពេញលក្ខខណ្ឌនៃការឃុំឃាំងរបស់គេ នឹងត្រូវបានចាត់ទុកជាពលកម្មដោយបង្ខំ។ អ្នកទោស

K

ដែលទទួលយកការងារដោយស្ម័គ្រចិត្តជាផ្នែកមួយនៃការស្តារនីតិសម្បទា មិនត្រូវបានចាត់ទុកថាជាពលកម្មដោយបង្ខំនោះទេ។ ច្បាប់ដែលមានស្រាប់ទាំងអស់មិនបានបញ្ជាក់ពីពលកម្មពន្ធនាគារដែលផ្តល់នូវក្តីបារម្ភដល់អ្នកនាំចូល និងអាចនាំទៅរកការរិតត្បិតការបើកទីផ្សារនាំចូល។ សន្ធិសញ្ញាអន្តរជាតិទាំងនេះ មិនអាចកែប្រែបានទេ។

ដូចនេះយើងត្រូវការបទប្បញ្ញត្តិជាក់លាក់ដើម្បីដោះស្រាយជាមួយពលកម្មពន្ធនាគារ។

<u>ជម្រើសដទៃទៀត</u>

៣.ខ. ជម្រើសដ៏ទៃទៀតដែលអាចអនុវត្តបាន (សម្រាប់កាវិភាគលើផលប៉ះពាល់)

១. ការហាមឃាត់ទាំងស្រុងចំពោះពលកម្មពន្ធនាគារ។

២. ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ។

៣. កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ។

៣.គ. ជម្រើសដ៏ទៃទៀតដែលតាមទ្រឹស្តីអាចមាន ប៉ុន្តែមិនអាចអនុវត្តបាន (មិនទាមទារនូវការវិភាគបន្ថែមទៀតទេលុះណាតែមានការប្រែប្រួលក្នុងកំឡុងពេលនៃដំណើការនៃការRIA)

៤. អនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមារដល់កម្មករដែលជាអ្នកទោស និងណែនាំពីប្រាក់លើកទឹកចិត្តដទៃទៀតសម្រាប់ម៉ោងការងាររបស់ពួកគេ។

## ៤. ការប៉ាន់ស្មានបឋមនៃចំណាយកាតព្វកិច្ចនិងផលប៉ះពាល់ចំពោះការប្រគួតប្រជែង

៤.១. <u>ការកំណត់នូវភារកិច្ច និងប្រភេទចំណាយ(tasks and cost-categories)</u>

*គោលការណ៍ណែនាំផ្តល់នូវតារាងនៃប្រភេទចំណាយដែលអាចមាន*

| អត្ថាធិប្បាយអំពីជម្រើស | ភារកិច្ច និងប្រភេទចំណាយដែលវិស័យសាធារណៈត្រូវរ៉ាប់រងដើម្បីបង្កើត អនុវត្ត និង ប្រតិបត្តិជម្រើសនោះ | ភារកិច្ច និងប្រភេទចំណាយដែលវិស័យឧស្សាហកម្មត្រូវរ៉ាប់រងដើម្បីអនុវត្តតាមជម្រើសនោះ |
|---|---|---|
| សំណើរ | គួរតែស្វែងរកឱកាសដែលជាជម្រើសផ្សេងៗ សម្រាប់អ្នកទោសក្នុងការ | ការចំណាយលើពលកម្មខ្ពស់ |

18

| | | |
|---|---|---|
| | កសាងសមត្ថភាព ជំនាញ និងអាចសម្របខ្លួនចូលក្នុងសង្គមបាន។ល។ | |
| ជម្រើសទី១: ការហាមឃាត់ទាំងស្រុងចំពោះពលកម្មពន្ធនាគារ | មានលក្ខណៈធ្ងន់ធ្ងរជាងសំណើរដែលបានស្នើ ដោយសារការហាមឃាត់នេះត្រូវបានធ្វើឡើងចំពោះផលិតកម្មក្នុងស្រុកនិងផលិតកម្មសម្រាប់នាំចេញ។ | ការចំណាយពលកម្មមានតម្លៃថ្លៃច្រើនជាងសំណើរ |
| ជម្រើសទី២: ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ | រាជរដ្ឋាភិបាល ចំណាយលើមន្ត្រីអធិការកិច្ច(មួយផ្នែក)។ ការចំណាយលើមន្ត្រីអធិការកិច្ច (ILO) មានបរិមាណច្រើនជាងមន្ត្រីអធិការកិច្ចក្នុងស្រុក ដោយសារមន្ត្រីអធិការកិច្ចរបស់ ILO មិនមែនជាអ្នកក្នុងស្រុក។ | ឧស្សាហកម្ម ក៏ត្រូវចំណាយដែរ (សម្រាប់ផ្នែកដែលនៅសល់ ត្រូវចំណាយដោយធានាគារពិភពលោក) |
| ជម្រើសទី៣:កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ | ស្រដៀងនឹងសំណើរ។ | ស្រដៀងនឹងសំណើរ។ |

ឱកាសសម្រាប់អ្នកទោសដើម្បីបម្រើការងារក្នុងអំឡុងពេលស្ថិតក្នុងពន្ធនាគារ ផ្តល់នូវការឧបត្ថម្ភនៃការបណ្តុះបណ្តាលឡើងវិញជាមួយនឹងការធ្វើសមាហរណកម្មម្តងទៀតក្នុងសង្គមដើម្បីកាត់បន្ថយការប្រព្រឹត្តបទល្មើសម្តងទៀតនិងកាត់បន្ថយភាពតានតឹងដែលកើតឡើងដោយសារការជាប់ពន្ធនាគារយូរ។ អ្នកទោសក៏អាចរកចំណូល ដែលអាចអភិវឌ្ឍនូវសុខុមាលភាពខណៈពេលស្ថិតក្នុងពន្ធនាគារ។ ជម្រើសទាំងឡាយណាដែលធ្វើការហាមឃាត់ទាំងស្រុងនូវពលកម្មពន្ធនាគារ នឹងធ្វើបាត់បង់នូវអត្ថប្រយោជន៍ទាំងនេះ។

៤.២. <u>វិសាលភាពនៃជម្រើស</u>

*ចូររៀបរាប់វិស័យឬប្រភេទធុរកិច្ចដែលរងឥទ្ធិពលព្រមទាំងធ្វើការព្យាករណ៍ផលប៉ះពាល់ពីការអនុវត្តតាមជម្រើសដែលបានស្នើឡើង (សូមផ្តល់ភស្តុតាងដើម្បីគាំទ្រការប៉ាន់ស្មាននេះ)។*

| ជម្រើស (មើល ៤.១) | វិស័យធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|

18

| | | | |
|---|---|---|---|
| សំណើរ | -ម្ចាស់រោចក្រនិងផលិតករទាំងអស់នៃទំនិញអាចនាំចេញទំនិញរបស់ពួកគេគ្រប់ពេលវេលា។<br>-គ្រប់ពន្ធនាគារនិងអ្នកជាប់ក្នុងពន្ធនាគារទាំងអស់នៅក្នុងប្រទេសកម្ពុជា | -ស្ទើរគ្រប់រោងចក្រកាត់ដេរកាត់ដេរសំលៀកបំពាក់និងស្បែកជើងទាំងអស់ដែលមានទីតាំងនៅជិតពន្ធនាគារ<br><br>-ពន្ធនាគារនៅខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និងពន្ធនាគារដទៃទៀតដែលមានទីតាំងនៅក្បែររោងចក្រ<br><br>-អ្នកទោសដែលស្ថិតនៅក្រោមគម្រោងស្តារនីតិសម្បទានិង និងក្នុងក្រុមជាក់លាក់ណាមួយ | ការស្ទង់មតិជាលក្ខណៈឯកជន |
| ជម្រើសទី១. ការហាមឃាត់ទាំងស្រុងចំពោះ | ដូចខាងលើ | ដូចខាងលើ | ដូចខាងលើ |

| | | | |
|---|---|---|---|
| ពលកម្មពន្ធនាគារ | | | |
| ជម្រើសទី២. ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ | ដូចខាងលើ | ដូចខាងលើ | ដូចខាងលើ |
| ជម្រើសទី៣. កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ | មានតែវិស័យកាត់ដេរតែប៉ុណ្ណោះ | ប្រហែល ៣២០រោងចក្រ | ពតិមានទទួលបានពី TPD/MoC |

៤.៣. <u>ប៉ាន់ស្មានកម្រិតកំណើននៃចំណាយកាតព្វកិច្ចរបស់ធុរកិច្ចនិងរបស់រាជរដ្ឋាភិបាល</u>

| ធុរកិច្ច | កម្រឹតនៃចំណាយកាតព្វកិច្ច | អំណះអំណាង |
|---|---|---|
| សំណើរ | មិនគួរឲ្យកត់សម្គាល់ | មានតែពន្ធនាគារដែលនៅជិតរោងចក្រប៉ុណ្ណោះនឹងទទួលរងផលប៉ះពាល់។ ហើយមានតែផ្នែកខ្លះនៃពលកម្មពន្ធនាគារប៉ុណ្ណោះ អាចត្រូវបានប្រើប្រាស់ដោយសារតែវាជាការស្ម័គ្រចិត្ត និងមានតែមុខងារមួយចំនួនប៉ុណ្ណោះដែលត្រូវបំពេញដោយអ្នកទោស។ មានអ្នកទោសដែលមានសក្តានុពលចំនួនតិចជាង ២ ០០០នាក់ ត្រូវបានជួលក្នុងរោងចក្រ ដែលបច្ចុប្បន្នមានកម្មករសរុបចំនួន ១៦០ ០០០នាក់ ត្រូវបានប្រើប្រាស់ដោយរោងចក្រ។ |
| ជម្រើសទី១. ការហាម | មិនគួរឲ្យកត់សម្គាល់ | មានបរិមាណច្រើនជាងសំណើរ |

| | | |
|---|---|---|
| ឃាត់ទាំងស្រុងចំពោះពលកម្មពន្ធនាគារ | | ដោយសារការហាមឃាត់ទាំងស្រុងនឹងកាត់បន្ថយឱកាសរបស់អ្នកទោស បង្កើនប្រាក់ចំណាយរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់ជម្រើសផ្សេងៗក្នុងការបណ្តុះបណ្តាលនិងការស្តានីតិសម្បទាអ្នកទោស។ តែទោះបីជាយ៉ាងណាការប៉ះពាល់នៅតែទំនងជាមិនច្រើន។ |
| ជម្រើសទី២. ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរបស់អង្គការពលកម្មអន្តរជាតិដើម្បីធ្វើឲ្យប្រសើរឡើងដល់រោងចក្រកម្ពុជា | មិនគួរឲ្យកត់សម្គាល់ | មានបរិមាណច្រើនជាងជម្រើសទី១ ដោយសារការចំណាយកាតព្វកិច្ចលើមន្ត្រីអធិការកិច្ចមកពីក្រៅប្រទេស(ILO) ទំនងជាខ្ពស់ជាងមន្ត្រីអធិការកិច្ចក្នុងស្រុក។ តែទោះបីជាយ៉ាងណាការប៉ះពាល់នៅតែទំនងជាមិនច្រើន។ |
| ជម្រើសទី៣. កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ | មិនគួរឲ្យកត់សម្គាល់ | ទំនងជាមានការប៉ះពាល់តិចជាងសំណើរ។ ទន្ទឹមនឹងនេះ ដំណោះស្រាយដទៃទៀតសម្រាប់វិស័យស្បែកជើងក៏ជាតម្រូវការផងដែរ។ |

| រាជរដ្ឋាភិបាល | កម្រិតនៃចំណាយកាតព្វកិច្ច | អំណះអំណាង |
|---|---|---|
| សំណើរ | មិនគួរឲ្យកត់សម្គាល់ | ការចំណាយលើមន្ត្រីអធិការកិច្ច-ការធ្វើអធិការកិច្ចចំពោះពន្ធនាគារដែលនៅជិតរោងចក្រ។ សន្មតថា មាន៥រោចក្រ@ $២០០/មួយខែ=$១០០០ មួយឆ្នាំ $១២០០០។ |
| ជម្រើសទី១. ការហាម | មិនគួរឲ្យកត់សម្គាល់ | ស្រដៀងនឹងសំណើរ, $១២០០០ |

K

| | | |
|---|---|---|
| ឃាត់ទាំងស្រុងចំពោះពលកម្មពន្ធនាគារ | | ក្នុងមួយឆ្នាំឬតិចជាង |
| ជម្រើសទី២. ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ | មិនគួរឲ្យកត់សម្គាល់ | ខ្ពស់ជាងជម្រើសទី១ ខណៈពេលដែលប្រាក់ខែនៃមន្ត្រីអធិការកិច្ចរបស់ ILO ជាធម្មតាខ្ពស់ជាងអ្នកក្នុងស្រុក។ |
| ជម្រើសទី៣. កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ | មិនគួរឲ្យកត់សម្គាល់ | តិចជាងជម្រើសទី១។ |

៤.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | កម្រិតនៃផលចំណេញ | មូលហេតុ |
|---|---|---|
| សំណើ | គួរឲ្យកត់សម្គាល់ | សហរដ្ឋអាមេរិកជាទីផ្សារធំជាងគេបំផុត ដូចនេះស្ទើរតែ ៧០%នៃទីផ្សារត្រូវបានគំរាមគំហែង។ ហើយប្រទេសដទៃ(សហគមន៍អឺរ៉ុប) ប្រហែលជាយកគំរូតាម។ សំណើរនេះនឹងកាត់បន្ថយការគំរាមគំហែងខាងលើ។ |
| ជម្រើសទី១. ការហាមឃាត់ទាំងស្រុងចំពោះពលកម្មពន្ធនាគារ | គួរឲ្យកត់សម្គាល់ | ស្រដៀងនឹងសំណើប៉ុន្តែជម្រើសទី១នឹងមានប្រសិទ្ធភាពបំផុត ~~ជាង~~ក្នុងការកាត់បន្ថយហានីភ័យចំពោះការបដិសេធទំនិញនិងការហាមឃាត់ |
| ជម្រើសទី២. ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ | គួរឲ្យកត់សម្គាល់ | ស្រដៀងនឹងសំណើ។ |

| | | |
|---|---|---|
| ជម្រើសទី៣. កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ | គួរឲ្យកត់សម្គាល់ | ស្រដៀងនឹងសំណើ។ |

៤.៥. <u>តើមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរឬទេ?</u> មែន/មិនមែន*(គូសរង្វង់និងដាក់លេខយោងនៃគោលការណ៍ណែនាំ។ផលប៉ះពាល់លើការប្រកួតប្រជែងតែងតែឱ្យមានRIS)*។

| |
|---|
| រោងចក្រធំៗបានប្រើប្រាស់ពលកម្មពន្ធនាគារច្រើន។ ហើយមានតែរោងចក្រជិតពន្ធនាគារប៉ុណ្ណោះដែលប្រើប្រាស់ពលកម្មពន្ធនាគារ។ សំណើបញ្ញត្តិកម្មនេះ ទំនងជាប៉ះពាល់ដល់រោងចក្រទាំងនេះ។ ទោះបីយ៉ាងណា ផលប៉ះពាល់ទំនងជាមិនមានលក្ខណៈអ្វីគួរឲ្យកត់សម្គាល់ឡើយ ដោយសារតែសមាមាត្រនៃការប្រើប្រាស់ពលកម្មពន្ធនាគារមានកម្រិតទាប។ |

៤.៦. <u>តើមានផលប៉ះពាល់លើយេនឌ័រដែរឬទេ?</u>

តើបញ្ញត្តិកម្មនេះមានឥទ្ធិពលមកលើស្ត្រី (រូបវន្តបុគ្គលនិងស្ត្រីដែលកាន់កាប់ធុរកិច្ច) ច្រើនជាងបុរសដែរឬទេ?

មែន / មិនមែន

បើ "មិនមែន" សូមបន្តទៅផ្នែកទី៥

បើ "មែន" ចូរអធិប្បាយនូវផលប៉ះពាល់

| |
|---|
| កម្មកររោងចក្រកាត់ដេរភាគច្រើនជាស្ត្រី ប៉ុន្តែអ្នកទោសភាគច្រើនជាបុរស។ ដូចនេះ វានឹងមានការផ្លាស់ប្តូរតិចតួចក្នុងការប្រើប្រាស់កម្មករស្ត្រីទៅអ្នកទោសជាបុរស។ ការផ្លាស់ប្តូរនេះ ទំនងជាមានបរិមាណតិច។ |

តើផលប៉ះពាល់គួរឱ្យកត់សម្គាល់ដែរឬទេមែន ? / មិនមែន

បើ "មិនមែន" សូមបន្តទៅផ្នែកទី៥

បើ "មែន" ចូរបង្ហាញភស្តុតាងថាបញ្ញត្តិកម្មនេះពិតជាជះឥទ្ធិពលទៅលើស្ត្រីច្រើនជាង:

| |
|---|
| មិនអាចអនុវត្តបាន។ |

ររ

តើអ្នកអាចវាស់វែងផលប៉ះពាល់បានដែរ ឬទេ?បាន /មិនបាន

បើអាចធ្វើបាន ប្រាប់ពីបរិមាណ។

## ៥. កិច្ចពិគ្រោះយោបល់បឋម

ពិគ្រោះយោបល់ជាមួយតំណាងអ្នកពាក់ព័ន្ធ។ កិច្ចពិគ្រោះយោបល់នេះមានគោលបំណងធ្វើឲ្យចំណុចដែលបានធ្វើខាងលើកាន់តែប្រសើរឡើង។សេចក្តីលំអិតនៃកិច្ចពិគ្រោះយោបល់នេះអាចធ្វើឡើងតាមក្រោយប្រសិនបើតម្រូវឲ្យមានរបាយការណ៍RIS ចុងក្រោយ។

ចូរធ្វើវាឲ្យដូចជាដំណើរការប្រជុំប្រមូលគំនិត(brainstorming session) ឬការពិគ្រោះយោបល់ជាក្រុម (focus group interviews).

| ក្រុម | សហគ្រាស<br>សមាគមឧស្សាហកម្ម (តំណាង ឲ្យ% នៃឧស្សាហកម្ម) | វិធីសាស្រ្ត | សង្ខេបទស្សនៈ |
|---|---|---|---|
| ផលិតករ | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ៩៥% | - ការស្ទង់មតិជាឯកជន<br>- ការសួរសំនួរនិងប្រជុំ | អ្នកភាគច្រើនបាននិយាយថា ទីផ្សារនឹងត្រូវបានគំរាមគំហែងប្រសិនបើគ្មានប្រកាសនេះទេ។ តែទោះជាយ៉ាងណាមានសមាជិកខ្លះ ត្រូវការបត់បែន។ |
| | សហគ្រាស (ធំ/មធ្យម/តូច)<br>ភាគច្រើនជាសហគ្រាសធំ | ដូចខាងលើ | |
| អ្នកប្រើប្រាស់ | ក្រុមអ្នកប្រើប្រាស់ | មិនអាចអនុវត្តបាន | |
| | អ្នកប្រើប្រាស់ធំៗ (ឧ. អ្នកប្រើប្រាស់ដែលជាឧស្សាហករ)<br>អ្នកបោះដុំទំនិញ | អ្នកនាំចូលធំៗក្រៅប្រទេស | ទីផ្សារសហរដ្ឋអាមេរិកមានកូតាច្រើន ដែលតម្រូវឲ្យមានការហាមឃាត់ពលកម្មពន្ធនាគារ |
| | អ្នកទិញទំនិញដែលលក់រាយ | មិនអាចអនុវត្តបាន | |
| សង្គមស៊ីវិល/អង្គការក្រៅរាជរដ្ឋាភិបាល | អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក | ការស្ទង់មតិជាឯកជននិងការប្រជុំ | អង្គការក្រៅរដ្ឋាភិបាលភាគច្រើនគាំទ្រសំណើនេះ ប៉ុន្តែតម្រូវឲ្យមានភាពបត់ |

| | | | |
|---|---|---|---|
| | | | បែនក្នុងការអនុវត្ត ដើម្បីផ្តល់ឱកាសសម្រាប់កម្មវិធីស្តានីតិសម្បទាសម្រាប់អ្នកទោស |
| រាជរដ្ឋាភិបាល | ក្រសួង/ស្ថាប័ន | ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | គ្រប់ក្រសួងទាំងអស់គាំទ្រសំណើនេះ |
| យេនឌ័រ | ក្រុមស្ត្រី | គ្មានការពិគ្រោះយោបល់ | |
| អ្នកជំនាញ | អ្នកជំនាញរបស់ អង្គការពលកម្មពិភពលោក ធនាគារពិភពលោក/ធនាគារអភិវឌ្ឍន៍អាស៊ី | គ្មានការពិគ្រោះយោបល់ | |
| ជាសាធារណៈ | វេទិការសាធារណៈថ្ងៃទី៣ខែមីនា | ការប្រជុំជាសាធារណៈ | ការប្រជុំបានឯកភាពទៅលើសារៈសំខាន់នៃសំណើនេះ ព្រមទាំងជំរុញឲ្យមានការហាមឃាត់ពលកម្មពន្ធនាគារសម្រាប់វិស័យនាំចេញ។ ប៉ុន្តែក៏នៅមានការជជែកមួយចំនួនទៅលើនិយមន័យនៃពលកម្មដោយបង្ខំប្រៀបធៀបទៅនឹងពលកម្ម |

| | | | |
|---|---|---|---|
| | | | ដោយមានការព្រមព្រៀងដែលជាទូទៅត្រូវបានអនុវត្តនៅក្នុងកម្មវិធីស្តារនីតិសម្បទា។ ពត៌មានបន្ថែមនៃលទ្ធផលនៃការប្រជុំត្រូវត្រូវបានគូសបញ្ជាក់នៅផ្នែកខាងក្រោម។ |

សិក្ខាសាលាថ្ងៃទី៣ខែមីនា បានបញ្ជាក់ថា៖

- តម្រូវការដើម្បីបញ្ជាក់ឲ្យបានច្បាស់រវាងពលកម្មដោយបង្ខំនិងពលកម្មពន្ធនាគារដើម្បីស្វែងរកភាពខុសគ្នា ព្រមទាំងដើម្បីធានាថា ការប្រើប្រាស់ពលកម្មត្រូវបានប្រើដើម្បីបំពេញតាមលក្ខខណ្ឌការឃុំឃាំងអ្នកទោស- ពលកម្មទាំងនេះ គួរតែត្រូវបានប្រើក្នុងការងារសាធារណៈ។
- ធ្វើការបញ្ជាក់អំពីហានិភ័យខ្ពស់នៃការអនុញ្ញាតឲ្យប្រើពលកម្មពន្ធនាគារដើម្បីផលិតទំនិញសម្រាប់នាំចេញ។
- អង្គការពលកម្មអន្តរជាតិនឹងធ្វើយុទ្ធនាការផ្សព្វផ្សាយដើម្បីអប់រំដល់ម្ចាស់រោងចក្រអំពីតម្រូវការនៃច្បាប់និងសិទ្ធិរបស់អ្នកទិញក្រៅប្រទេសក្នុងការបដិសេធទទួលទំនិញដែលសង្ស័យថាមានការប្រើប្រាស់ពលកម្មពន្ធនាគារ។
- ជាឧទាហរណ៍នៃប្រទេសអឺរ៉ុប ដែលបានប្រឈមមុខនឹងបញ្ហាទាំងនេះនិងឧបសគ្គនៃការអប់រំលើកម្មវិធីស្តារនីតិសម្បទារបស់ពួកគេឡើងវិញ និងការអប់រំដល់ម្ចាស់រោងចក្រអំពីលក្ខខណ្ឌទាំងនេះ
- ហានិភ័យខ្ពស់ចំពោះវិស័យផ្សេងៗទៀត របស់អ្នកទិញក្រៅប្រទេសក្នុងការបដិសេធនូវការបញ្ជាទិញពីប្រទេសកម្ពុជា
- ផលិតផលកសិកម្ម នឹងក្លាយជាឧបសគ្គមួយយ៉ាងជាក់លាក់ក្នុងការកំណត់អត្តសញ្ញាណប្រភពដើមតាមរយៈសង្វាក់ផលិតកម្ម។ ជម្រើសដែលអាចមានចំពោះទំនិញនាំចេញភាគច្រើនមានដូចជាកៅស៊ូនិងអង្ករ នឹងមិនត្រូវបានដាំដុះដោយប្រើប្រាស់ពលកម្មពន្ធនាគារនោះទេ។

## ៦.សន្និដ្ឋាន

### ៦.១: សេចក្តីសង្ខេបនៃការចំណាយបន្ថែមនិងផលចំណេញ

| ជម្រើស | បន្ទុកចំណាយរបស់វិស័យឧស្សាហកម្ម | បន្ទុកចំណាយរបស់វិស័យសាធារណៈ | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១: ការហាមឃាត់ទាំងស្រុងចំពោះពលកម្មពន្ធនាគារ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី២: ដំណើរការនៃការត្រួតពិនិត្យក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់អង្គការពលកម្មអន្តរជាតិ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី៣: កិច្ចព្រមព្រៀងរវាងសមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) និងក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងពលកម្មពន្ធនាគារ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |

៦.២. តើចាំបាច់ធ្វើRIS ដែរឬទេ?

- ចាំបាច់- សូមបញ្ចប់ការវាយតម្លៃបឋមហើយចាប់ផ្តើមរៀបចំ RIS។
- មិនចាំបាច់- ផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃបឋមPAដែលនៅសល់។

*(សូមគូសរង្វង់លើ"ចាំបាច់" ឬ "មិនចាំបាច់" ដោយផ្អែកទៅលើកម្រិតនៃភាពសំខាន់នៃចំណាយកាតព្វកិច្ចនិងផលចំណេញហើយពិចារណាផងថាតើមានផលប៉ះពាល់លើការប្រកួតប្រជែងដែរឬទេ)។*

| |
|---|
| RIS សម្រាប់សំណើនេះនឹងមិនត្រូវបានរៀបចំនោះទេ ដោយសារការវាយតម្លៃបឋមបញ្ជាក់ថាការប៉ះពាល់នៃប្រកាសនេះលើការចំណាយធុរកិច្ចនឹងមិនមានលក្ខណៈគួរឲ្យកត់សម្គាល់ទេ ដោយធ្វើការប្រៀបធៀបចំនួនបរិមាណពលកម្មពន្ធនាគារដែលមានចំនួនតិចធៀបជាមួយនឹងពលកម្មរោងចក្រសរុប។ |

18

៦.៣. ជម្រើសដែលបានជ្រើសរើស (សូមអធិប្បាយអំពីជម្រើស)

| |
|---|
| ប្រកាសដែលបានស្នើឡើង បានហាមឃាត់នូវការប្រើប្រាស់ពលកម្មពន្ធនាគារក្នុងរោងចក្រ ឬផលិតទំនិញដែលនឹងត្រូវនាំចេញពីប្រទេសកម្ពុជា។ ដូចនេះ ពន្ធនាគារអាចអនុញ្ញាតឲ្យអ្នកទោសចូលរួមក្នុងវិស័យរោងចក្រឬផលិតកម្មផ្សេងៗទៀតដែលជាផ្នែកមួយនៃការស្តារនិតិសម្បទារបស់ពួកគេឡើងវិញ ប៉ុន្តែក្នុងករណីដែលទំនិញទាំងនោះត្រូវបានលក់តែក្នុងទីផ្សារក្នុងស្រុកប៉ុណ្ណោះ។<br><br>ជម្រើសនេះ នឹងមិនដាក់លក្ខខណ្ឌឬទណ្ឌកម្មលើពន្ធនាគារឬអ្នកទោសឡើយ។ ជំនួសមកវិញធុរកិច្ចដែលជាប់ពាក់ព័ន្ធក្នុងការផលិតឬនាំចេញទំនិញសម្រាប់លក់នៅបរទេស ត្រូវបង្ហាញថាទំនិញទាំងនេះគឺត្រូវបានផលិតដោយមិនប្រើប្រាស់ពលកម្មពន្ធនាគារ។<br><br>ចំពោះធុរកិច្ចណាដែលទទួលទំនិញដែលផលិតដោយប្រើប្រាស់ពលកម្មពន្ធនាគារ រួចហើយធ្វើការនាំចេញទំនិញទាំងនោះ នឹងទទួលរងការដាក់ទណ្ឌកម្ម។ ប្រការនេះ ដូចគ្នានឹងជម្រើសទីមួយ។ ការបំពានច្បាប់លើកដំបូង នឹងទទួលរងការផាកពិន័យជាទឹកប្រាក់ចំនួន ៥០០០០$ និងការហាមឃាត់ការនាំចេញរយៈពេលបីខែ។ ទណ្ឌកម្មទាំងនេះ គឺត្រូវអនុវត្តចំពោះអ្នកនាំចេញនិងអ្នកជាប់កិច្ចសន្យាផលិតបន្តទាំងឡាយណាដែលជាប់ពាក់ព័ន្ធក្នុងដំណើរការផលិតកម្មរវាងទំនិញដែលចេញពីពន្ធនាគារនិងត្រូវបានគេនាំចេញ។ ក្នុងករណីមានការបំពានច្បាប់ម្តងទៀត ធុរកិច្ចនឹងទទួលរងការដកហូតសិទ្ធិក្នុងការនាំចេញនៃធុរកិច្ចដែលជាប់ពាក់ព័ន្ធ ដោយក្រសួងពាណិជ្ជកម្ម។ |

| លក្ខណៈវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានបន្ទុកចំណាយអប្បបរមាសម្រាប់វិស័យឧស្សាហកម្មនិងសហគមន៍ដែរឬទេ? | មែន | |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មិនមែន | ការហាមឃាត់ពលកម្មពន្ធនាគារ គឺមិនមែនជាការហាមឃាត់ទាំងស្រុងនោះទេ ហើយនឹងនៅតែមានហានិភ័យដែលនៅសល់ ប្រសិនអាចប្រើប្រាស់ពលកម្មពន្ធនាគារត្រូវបានប្រើដើម្បីផលិតទំនិញសម្រាប់នាំចេញ ធ្វើឲ្យអ្នកនាំចូលឈប់នាំចូលទំនិញពីកម្ពុជា ដូចនេះចំណុចជាសក្តានុពលនៅសល់នោះគឺថា អ្នកទិញបរទេសមួយចំនួននឹងឈប់នាំចេញនូវទំនិញ |

| | | |
|---|---|---|
| | | ពីប្រទេសកម្ពុជា។<br>ការហាមឃាត់ទាំងស្រុងនឹងផ្តល់ផលប្រយោជន៍ជាក់លាក់និងច្រើនបំផុត។ |
| តើវាជាជម្រើសដែលមានហានិភ័យអប្បបរមាសម្រាប់សាធារណៈដែរឬទេ? | មិនមែន | ដូចខាងលើ។ |

ប្រសិនបើចម្លើយទាំងអស់សុទ្ធតែ "មែន" សូមបន្តទៅចំណុចទី៧។

ប្រសិនបើមានចម្លើយណាមួយខាងលើ"មិនមែន"តើហេតុអ្វីបានជាជម្រើសនេះត្រូវបានជ្រើសរើស?*(សូមគូស"x" ក្នុងប្រអប់មួយ)*

☐ ទោះបីជាលក្ខណៈវិនិច្ឆ័យមួយឬពីរខាងលើអវិជ្ជ មានតែការរួមបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យទាំងអស់មានលក្ខណៈសមស្រប។ចូរផ្តល់អំណះអំណាងនិងបន្តទៅចំនុចទី៧

ផលប្រយោជន៍នៃការប្រើប្រាស់ពលកម្មពន្ធនាគារក្នុងផលិតកម្មទំនិញសម្រាប់ទីផ្សារក្នុងស្រុក (ឧទាហរណ៍៖ ការស្តារនីតិសម្បទាសម្រាប់អ្នកទោស) ត្រូវបានប៉ាន់ប្រមាណថាសំខាន់ជាងហានីភ័យដែលនៅសល់។ ផែនការដែលបានគ្រោងទុកក្នុងការអនុវត្តឲ្យមានប្រសិទ្ធិភាពនឹងជួយកាត់បន្ថយហានីភ័យដែលនឹងកើតមាននេះ។

☐ មានកត្តាផ្សេងទៀតមានឥទ្ធិពលលើការសម្រេចចិត្ត[មើលអត្ថបទខាងក្រោម]

តើកត្តាផ្សេងណាខ្លះត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសជម្រើសនេះ?

ចូរពន្យល់អំពីកាលៈទេសៈនិងបញ្ជាក់ពីអំណះអំណាង?

| កត្តាជះឥទ្ធិពល | កាលៈទេសៈ | អំណះអំណាង |
|---|---|---|
| មិនមាន | មិនមាន | មិនមាន |

៧. អនុវត្ត

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| សំណើនេះ នឹងត្រូវចាប់ផ្តើមអនុវត្តឲ្យបានលឿនតាមតែអាចធ្វើទៅបាន ដើម្បីចៀសវាងនូវផលវិបាកផ្សេងៗ ដែលអាចកើតឡើងដល់ឧស្សាហកម្មនាំចេញ។ ដើម្បីសម្របសម្រួលក្នុងការអនុវត្ត |

18

ប្រកាសនេះ នឹងមានគណៈកម្មាធិការអាដហុកមួយដែលមានការព្រមព្រៀងនូវការត្រួតពិនិត្យរួមគ្នា ដើម្បីពិនិត្យឲ្យបានញឹកញាប់លើស្ថានភាពពន្ធធានាគារ និងចូលរួមក្នុងកម្មវិធីស្តារនីតិសម្បទា ដើម្បីធានាថាពលកម្មពន្ធធានាគារនឹងត្រូវបានប្រើប្រាស់តែក្នុងផលិតកម្មក្នុងស្រុកប៉ុណ្ណោះ។

៧.២. តើគួរធ្វើការពិនិត្យសំណើនេះឡើងវិញក្រោយពេលសំណើនេះត្រូវបានប្រតិបត្តិដែរឬទេ?បើដូច្នោះ តើបទប្បញ្ញត្តិនេះគួរត្រូវបានពិនិត្យឡើងវិញយ៉ាងដូចម្តេច និងនៅពេលណា?

សំណើនេះ ត្រូវបានគេបង្កើតឡើងដើម្បីឆ្លើយតបយ៉ាងរហ័សក្នុងការបញ្ចៀសបញ្ហាកើតឡើង ដែលបង្កឲ្យមាននូវផលវិបាកធ្ងន់ធ្ងរផ្សេងៗ។ ទំហំនៃបញ្ហាក៏ដូចជាប្រសិទ្ធភាពនៃការហាមឃាត់ គួរតែត្រូវបានត្រួតពិនិត្យយូរៗម្តង។

ជាឧទាហរណ៍ ប្រសិនបើសារព័ត៌មានសរសេរពីភាពអវិជ្ជមានពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មពន្ធនាគារនៅតែមានដោយសារតែសំណើនេះ នោះនឹងមានអំណាៈអំណាងមួយចំនួនក្នុងការកែតម្រូវច្បាប់ដើម្បីពង្រីកទំហំវិសាលភាពនៃច្បាប់នេះ។

ការចំណាយសម្រាប់ធុរកិច្ច អាចកើនឡើងបន្តបន្ទាប់ ខណៈពេលដែលកំលាំងពលកម្មក្នុងស្រុកស្វែងរកលក្ខខណ្ឌការងារដែលល្អប្រសើរ ដែលនឹងបង្កើនគំលាតរវាងការចំណាយលើពលកម្មពន្ធនាគារនិងពលកម្មសេរី។

## អត្ថាធិប្បាយផ្សេងទៀត

មិនមែន

| ដំណើរការ | ឈ្មោះ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | [illegible] (RIA) (Unit) | [signature] | [illegible] 11/5/2012 |
| ត្រួតពិនិត្យដោយ (ORIA) | Eng-Ratmoni | [signature] | 14/5/2012 |
| ឯកភាពដោយ (ORIA) | Pech Sokha | [signature] | 21/5/12 |
| បញ្ចូលទិន្នន័យដោយ | Roth [illegible] | [signature] | 14/5/2012 |
| បញ្ចូលក្នុងគេហទំព័រដោយ | [illegible] | [signature] | 22/5/12 |